ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកក្កដា និងទិសដៅការងារខែសីហា ឆ្នាំ២០១៤

នៅក្នុងខែកក្កដានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចាត់ចែងរៀបចំទីកន្លែងសម្រាប់ជំនួបកំពូលរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ដែលបានប្រព្រឹត្តទៅប្រកបដោយជោគជ័យដ៏ត្រចះត្រចង់ និងបានបំពេញការងារយ៉ាងសកម្ម លើការដ្ឋានជាច្រើនដោយផ្សារភ្ជាប់បទដ្ឋានការងាររដ្ឋបាល បច្ចេកទេស នីតិវិធី និងហិរញ្ញវត្ថុ ជាពិសេសការរៀបចំប្រជុំគណៈកម្មការជំនាញ គណៈកម្មាធិការអចិន្ត្រៃយ៍ សម័យប្រជុំពេញអង្គលើកទី៩ ចាត់ចែងដំណើរការនីតិវិធីថ្លង់គម្រោងថវិកាឆ្នាំ២០១៥ ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងសកម្មភាពការងារសង្គម និងខិតខំពង្រឹងពង្រីកភាពសុខដុមផ្ទៃក្នុង បង្កើនការសន្សំសំចៃខ្ពស់ បង្កើតសេវាថ្មីៗ កសាងគោលនយោបាយនានា បង្កើនកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ និងបំពេញការងារសំខាន់ៗមួយចំនួនទៀតដូចខាងក្រោម៖

**I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

-បានចាត់ចែងរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន០២លើក ប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០២លើក ពិធីធ្វើតេស្តមន្ត្រីរាជការ ត្រៀមតាំងស៊ប់ក្នុងមុខតំណែង ប្រជុំពិនិត្យ និងពិភាក្សាអំពីក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាព សម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភារយៈពេល១០ឆ្នាំ (២០១៤-២០២៤) និងចូលរួមប្រជុំពិភាក្សាការងារផ្សេងៗ ព្រមទាំងបានពិនិត្យសម្រេចលើឯកសារផ្សេងៗចំនួន៦៧៦ច្បាប់ ។

**១.សេវាទ្រទ្រង់មុខងារនីតិកម្ម៖**

-បានរៀបចំប្រជុំផ្ទៃក្នុងគណៈកម្មការជំនាញ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៤ ។

**២.សេវាទ្រទ្រង់មុខងារត្រួតពិនិត្យ /ព័ត៌មាន៖**

-បានចុះបំពេញការងារអមជាមួយសមាជិក-សមាជិកា គណៈកម្មការនានា របស់ព្រឹទ្ធសភាក្នុងជំនួបសវនាការជាមួយអគ្គនាយកពន្ធនាគារ ស្តីពីការគ្រប់គ្រងពន្ធនាគារ និងស្ថានភាពអ្នកជាប់



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ឃុំឃាំងក្នុងពន្ធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅក្រសួងមហាផ្ទៃ ។

-បានអមដំណើរសមាជិក-សមាជិកាគណៈកម្មការនានា របស់ព្រឹទ្ធសភា អញ្ជើញទៅធ្វើទស្សនកិច្ច នៅការដ្ឋានគំរោងវារីអគ្គិសនីស្ទឹងឬស្សីជ្រុំក្រោម និងគំរោងវារីអគ្គិសនីស្ទឹងតាតៃ ខេត្តកោះកុង និង មន្ត្រីរាជការបានចុះបេសកកម្ម ចំនួន០៤លើក ដើម្បីរៀបចំវេទិកា សិក្សាស្រាវជ្រាវប្រមូលព័ត៌មាន ដើម្បីត្រៀមរៀបចំវេទិកា និងសហការជាមួយអាជ្ញាធរមូលដ្ឋាន សម្រាប់ក្រុមគ្រូពេទ្យស្ម័គ្រចិត្តវៀតណាម ចុះព្យាបាលជំងឺជូនប្រជាពលរដ្ឋ ។

**៣.សេវាទទួលមុខងារតំណាង៖**

-ទទួលពាក្យបណ្តឹងចំនួន០៧ករណី និងបញ្ជូនលិខិតទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដោះស្រាយបានចំនួន០៣ករណី ។

-រៀបចំបែបបទ និងអមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចុះទៅតាមបណ្តាខេត្ត រាជធានីទូទាំងប្រទេសចំនួន៥៥លើក ដើម្បីសំណេះសំណាល ជួបពិភាក្សាការងារ សាកសួរសុខទុក្ខ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោល នយោបាយភូមិ-ឃុំ មានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវា សាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំង បានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៦៤លើក ។

**៤.ការងារអន្តរជាតិ៖**

-ទទួលជួបជាមួយឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ និងគណៈប្រតិភូព្រឹទ្ធសភាឥណ្ឌូនេស៊ី ។

-ទទួលដំណើរទស្សនកិច្ចគណៈប្រតិភូសភាតំបន់ឥណ្ឌូនេស៊ី ដឹកនាំដោយអនុប្រធានគណៈកម្មការ អន្តរសភា ។

-រៀបចំបែបបទជូនគណៈប្រតិភូព្រឹទ្ធសភា ទៅចូលរួមកិច្ចប្រជុំប្រើប្រាស់ភាសាបារាំង(APF) និងទស្សនកិច្ចសិក្សាស្វែងយល់អំពីបទពិសោធន៍ក្នុងការរៀបចំក្រមសីលធម៌ សម្រាប់សមាជិកព្រឹទ្ធសភា និងការគ្រប់គ្រងចំណូលពីប្រេង និងឧស្ម័នធម្មជាតិ នៅប្រទេសកាណាដា ទស្សនកិច្ចសិក្សា ស្វែងយល់អំពីវិស័យកសិឧស្សាហកម្ម និងការចិញ្ចឹមសត្វ នៅទីក្រុងBudapeat ប្រទេស Hungry ចូលរួមកិច្ចប្រជុំកសាង និងការអនុវត្តគោលនយោបាយគ្រឿងស្រវឹងប្រកបដោយប្រសិទ្ធភាព នៅ ប្រទេសស្រីលង្កា ។

-រៀបចំបែបបទជូនមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅទស្សនកិច្ចសិក្សានៅប្រទេសថៃ

ស្តីពីកម្មវិធីភាពជាអ្នកដឹកនាំវ័យក្មេង ឆ្នាំ២០១៤ ។

-បំពេញបេសកកម្ម ក្នុងការកៀរគរជំនួយ និងកិច្ចសហប្រតិបត្តិការជូនស្ថាប័នព្រឹទ្ធសភា នៅប្រទេសបារាំង

-ទំនាក់ទំនងជាមួយដៃគូអន្តរជាតិនានា (ឥណ្ឌា ប្រ៊ុយណេ ហ្វីលីពីន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី វៀតណាម ថៃ រុស្ស៊ី អាល្លឺម៉ង់ អូស្ត្រាលី ស្ថានកុងស៊ុលបែលហ្ស៊ិក ស្ថានកុងស៊ុលន័រវេស ) ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

**៥.ទំនាក់ទំនងសាធារណៈ៖**

-ទំនាក់ទំនងជាមួយស្ថានីយ៍ទូរទស្សន៍ជាតិ ទូរទស្សន៍អាស៊ីអាគ្នេយ៍ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់ព្រឹទ្ធសភា និងសាកលវិទ្យាល័យ CUS, CMTC, CDC, AEU, ECCC, CWF, NIDA, Hong kong Center សាកលវិទ្យាល័យមេគង្គកម្ពុជា សាកលវិទ្យាល័យន័រតុន និងចំរើនពហុបច្ចេកវិទ្យា ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត សាធារណៈជន ចូលអានសៀវភៅ ចំនួន៤៥៨នាក់ និងអ្នកគ្រូ លោកគ្រូ មកពីខេត្តសៀមរាប ក្រុមអនាគតយុវជនកម្ពុជាអាស៊ាន ចំនួន២០នាក់ ក្រុមនិស្សិត Summer School នៃសាកលវិទ្យាល័យ Cologne ប្រទេសអាល្លឺម៉ង់ ចំនួន ៣៥នាក់ មកទស្សនកិច្ចសិក្សា និងនិស្សិតកូរ៉េមកធ្វើកម្មសិក្សានៅព្រឹទ្ធសភា ចំនួន១២នាក់ ។

**៦.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-បើកវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន០៥វគ្គ ស្តីពីថ្នាក់ភាសាអង់គ្លេស វគ្គការគ្រប់គ្រងបណ្ណាល័យ វគ្គE-document and website mobile plant form វគ្គភាសាចិនក្រុម១(ជំហាន៨) និងក្រុម២ (ជំហាន៧) ។

-មន្ត្រីចំនួន០១រូប ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីអធិការកិច្ច និងត្រួតពិនិត្យ និង០៣រូប ចូលរួមវគ្គប្រព័ន្ធអប់រំនៅខេត្តគួយចូវ នៅប្រទេសចិន និង១៦រូបទៀត ចូលរួមវគ្គជំនាញភាសាអង់គ្លេស នៅប្រទេសថៃ ។

-អាហារូបករណ៍វគ្គបណ្តុះបណ្តាលរយៈពេលវែង ស្តីពី Development Policies and Practices នៅប្រទេសស្វីស ចំនួន០១នាក់ និងវគ្គAdministrative Management នៅប្រទេសចិន ចំនួន០៣ នាក់ ។

**៧.ការអភិវឌ្ឍស្ថាប័ន៖**

-រដ្ឋាភិបាលចិនយល់ព្រមសាងសង់អគារ១ខ្នង ជូនព្រឹទ្ធសភា (ការប្តូរលិខិតប្តូរសារជាផ្លូវការ) ។

-រដ្ឋសភាវៀតណាមកំពុងសិក្សាអំពីការបំពាក់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន នៅក្នុងព្រឹទ្ធសភាកម្ពុជា (ការសិក្សាបច្ចេកទេសជាមួយក្រុមហ៊ុនEZECOM ) ។

-ការរៀបចំជួសជុលឡើងវិញអតីតអគារសម្ព័ន្ធភាពជាតិឃុំ-សង្កាត់ ធ្វើជាមជ្ឈមណ្ឌលបច្ចេកវិទ្យាព័ត៌មាន អគារមូលនិធិខ្មែរអភិវឌ្ឍន៍ និងលាបជញ្ជាំង អគារជប៉ុនទី១ និងទី២, អគារអគ្គនាយក/អគ្គរង ។

-រឿងថ្មី: ត្រៀមអគារសំរាប់គណៈកម្មការទី១០ ព្រឹទ្ធសភា ។

**៨. ការងារផ្នែកពិធីការ សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែង៖**

-ចូលរួមពិធីគោរពព្រះវិញ្ញាណក្ខ័ន្ធ និងដង្ហែព្រះបរមអដ្ឋិ ព្រះករុណា ព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះករុណា ព្រះបរមរតនកោដ្ឋ ។

-ចូលរួមគោរពវិញ្ញាណក្ខ័ន្ធសព ឯកឧត្តម ប្រាក់ សុខ អនុប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអាកាសយានិកយោធា ០៤រូប ។

-រៀបចំប្រជុំត្រៀមលក្ខណៈរៀបចំសិក្ខាសាលាអបអរសាទរខួបលើកទី៦៦ ទិវាសិទ្ធិមនុស្ស ១០ ធ្នូ (លើកទី២) ។

-ប្រជុំពិនិត្យ និងពិភាក្សាអំពីក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភារយៈពេល១០ឆ្នាំ (២០១៤-២០២៤) ។

-ប្រជុំបូកសរុបលទ្ធផលការងារឆមាសទី១ ឆ្នាំ២០១៤ និងលើកទិសដៅការងារ សំរាប់ឆមាសទី២ ឆ្នាំ២០១៤ ។

-ធ្វើតេស្តមន្ត្រីរាជការ ត្រៀមតាំងស៊ប់ក្នុងមុខតំណែង ។

-បានផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីអាហារូបករណ៍រយៈពេលខ្លីនៅប្រទេសស៊ុយអែត សំរាប់ឆ្នាំសិក្សា ២០១៤-២០១៥ ។

-ប្រជុំការពារគម្រោងថវិកាព្រឹទ្ធសភា ឆ្នាំ២០១៥ កម្រិតជំនាញនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-រៀបចំរបាយការណ៍ចំណូល-ចំណាយថវិកាព្រឹទ្ធសភា ឆមាសទី១ ឆ្នាំ២០១៤ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ។

-រៀបចំរបាយការណ៍ជូនប្រធានគណៈកម្មការទី២ ស្តីពីស្ថានភាពថវិកាព្រឹទ្ធសភា ក្រោយការការពារថ្នាក់កម្រិតជំនាញ ។

-បើក និងផ្តល់ឯកសណ្ឋានជូនមន្ត្រីរាជការ ។

-រៀបចំទីកន្លែងសម្រាប់ជំនួបកំពូលរវាងគណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ។

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងកិច្ច

ប្រជុំ និងពិធីផ្សេងៗ ចំនួន១៦លើក ។

-ថតចម្លងឯកសារ ចំនួន៥៩សំណើ ចងក្រងឯកសារជាសៀវភៅ ចំនួន៤០ក្បាល ដោះស្រាយសំណើថវិកា ចំនួន៣០០សំណើ និងសម្ភារចំនួន៦៧សំណើ ព្រមទាំងផ្តល់សេវាដឹកជញ្ជូនចំនួន ១៦០លើក ។

-ទទួលកុំព្យូទ័រលើតុ(ខូច) ចំនួន០១គ្រឿង ប្រគល់កុំព្យូទ័រលើតុ ម៉ាស៊ីនព្រីនធ័រ ចំនួន០៤គ្រឿង និងបិទលេខកូដកុំព្យូទ័រលើតុ និង Ipad ចំនួន០៣គ្រឿង ។ បញ្ចូលហ្គាស ជួសជុល ម៉ាស៊ីនត្រជាក់ ទូទឹកកក បន្ទប់ទឹក ទូរស័ព្ទ ប្តូរអំពូល ព្រី កុងតាក់ សោទ្វារឈើ ទ្វារអូតូ ចំនួន១១៧គ្រឿង ។

-ជួសជុលកុំព្យូទ័រ ត្រួតពិនិត្យ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីខ្មែរ Unicode, Office ចុះតាមដាន Internet និង Network សរុបចំនួន៣៣គ្រឿង និងបាន Upload ព័ត៌មាន និងឯកសារផ្សេងៗ ចំនួន៦២ ប្រធានបទ ។

## II.ទិសដៅការងារខែសីហា ឆ្នាំ២០១៤

### ១.សេវាទទួលបន្ទុកខាងនីតិកម្ម៖

-ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំពេញអង្គព្រឹទ្ធសភា ។

- ការជ្រើសតាំងអនុប្រធានក្រុមប្រឹក្សាប្រឆាំងអំពើពុករលួយ
- ការធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុង

### ២.សេវាទទួលបន្ទុកខាងត្រួតពិនិត្យ/ ព័ត៌មាន៖

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត ។

### ៣.សេវាទទួលបន្ទុកខាងតំណាង៖

-ការរៀបចំវេទិកាសាធារណៈរបស់ក្រុមសមាជិកព្រឹទ្ធសភា តាមភូមិភាគ រួមទាំងវេទិកាក្រុមសមាជិកាព្រឹទ្ធសភា ។

### ៤.ការងារអន្តរជាតិ៖

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអង្គទូតនានា។

- អគ្គរដ្ឋទូតជប៉ុន
- អនុប្រធានព្រឹទ្ធសភាជប៉ុន

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បំពេញបេសកកម្មក្រៅប្រទេស រួមទាំងអគ្គលេខាធិការដ្ឋាន៖

- ទស្សនកិច្ចសិក្សានៅប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី ថៃ (ខែកញ្ញា២០១៤)
- គណៈប្រតិភូគណៈកម្មការទី៥ ទៅបំពេញទស្សនកិច្ច នៅសាធារណរដ្ឋប្រជាមានិតចិន

•ត្រៀមទទួលបដិសណ្ឋារកិច្ចគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភាជប៉ុន ដឹកនាំដោយអនុប្រធានព្រឹទ្ធសភាជប៉ុន

-កិច្ចសហប្រតិបត្តិការជាមួយ KOICA, JICA, CAMSERV, វៀតណាម ឥណ្ឌា ឥណ្ឌូនេស៊ី សិង្ហបុរី ម៉ាឡេស៊ី កូរ៉េ ចិន ប៊្រុយណេ វិទ្យាស្ថានធនាគារពិភពលោក វិទ្យាស្ថានសភាកម្ពុជា និងដៃគូផ្សេងទៀត ។

-បន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង/ក្រៅប្រទេស សំរាប់ព្រឹទ្ធសភាតាមរយៈវិទ្យាស្ថានសភាកម្ពុជា ។

**៥.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-ត្រៀមរៀបចំបែបបទជូនមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅចូលរៀនវគ្គការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគរុកោសល្យ និងវគ្គការប្រើប្រាស់ថាមពល និងការរៀបចំគម្រោងផែនការឲ្យមានប្រសិទ្ធភាព នៅប្រទេសស៊ិយអែត ។

-ជំរុញលើកកម្ពស់ចំណេះដឹង ជំនាញភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន និងយកចិត្តទុកដាក់ដល់ការពង្រឹងវិន័យ និងសណ្តាប់ធ្នាប់សាធារណៈ ។

**៦.ការងារផ្ទៃក្នុង សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែង៖**

-ដោះស្រាយការប្រឈមថ្មីៗ លេចចេញពីការដំណោះស្រាយនយោបាយ ( ការបង្កើតគណៈកម្មការទី១០,ទីកន្លែង/លេខាធិការដ្ឋាន,មធ្យោបាយ និងធនធាន, តួនាទី ភារកិច្ចរបស់គណៈកម្មការទី១០)។

-ការរៀងគម្រោងថវិកាឆ្នាំ២០១៩ របស់ព្រឹទ្ធសភា ក្នុងក្របខ័ណ្ឌនយោបាយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-សិក្សាអំពីការដាក់ឲ្យអនុវត្តអង្គភាពថវិកា សម្រាប់០៤អង្គភាព ជាជំហានដំបូង ។

-បន្តពង្រឹងដំណើរការកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងជំរុញការចាប់ផ្តើមដំណើរការរបស់អង្គភាពសវនកម្មផ្ទៃក្នុង ។

-គិតគូរអំពីការប្រលងផ្ទេរក្របខ័ណ្ឌ ការតាំងស៊ប់ក្នុងមុខតំណែង ការផ្តល់គ្រឿងឥស្សរិយយសដល់មន្ត្រីរាជការ ការបំពេញតម្រូវការរបស់នាយកដ្ឋានភូមិភាគ និងនាយកដ្ឋានហផ្សា ។

-បង្កើនសមត្ថភាពស្រាវជ្រាវអំពីឯកសារ និងទិន្នន័យបច្ចុប្បន្នភាពរបស់ជាតិ ដើម្បីពង្រឹងសមត្ថភាពការងារ ។

-ត្រៀមរៀបចំប្រជុំពិគ្រោះយោបល់ក្នុងកម្រិតអគ្គលេខាធិការដ្ឋាន ដើម្បីពិនិត្យលើឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងព្រឹទ្ធសភារយៈពេល១០ឆ្នាំ (២០១៨-២០២៨) និងទស្សនវិស័យនៃដំណើរការទៅមុខរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (២០១៨-២០២៨) ។

-តាមដានកំណែទំរង់រដ្ឋបាលសាធារណៈ ដើម្បីកែសំរួលច្បាប់ ស្តីពីលក្ខន្តិកមន្ត្រីរាជការក្រុមនីតិប្បញ្ញត្តិ

- "ក" មាន១៤+១០+៦ ថ្នាក់ត្រូវកែមក១៤ថ្នាក់
- "ខ" មាន១៤+១០+៦ ថ្នាក់ត្រូវកែមក១៤ថ្នាក់
- "គ" មាន១៤+១០+៦ ថ្នាក់ត្រូវកែមក១០ថ្នាក់
- "ឃ" លុបចោល ។

## III.សេចក្តីសន្និដ្ឋាន

ក្នុងខែកក្កដានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំប្រជុំគណៈកម្មការជំនាញ គណៈកម្មាធិការអចិន្ត្រៃយ៍ សម័យប្រជុំពេញអង្គលើកទី៥ ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៤ ជាពិសេសការរៀបចំទីកន្លែងសំរាប់ជំនួបកំពូលរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្រ្គោះជាតិដែលបានប្រព្រឹត្តទៅប្រកបដោយជោគជ័យដ៏ត្រចះត្រចង់ ។

ការអនុវត្តនូវដំណោះស្រាយនយោបាយនឹងបង្កើតឡើងនូវការប្រែប្រួលថ្មី ដែលពាក់ព័ន្ធនឹងគណៈកម្មការនានារបស់ព្រឹទ្ធសភាផងដែរ ។ នោះគឺបន្ទុកថ្មីបន្ថែមដែលឲ្យទិដ្ឋភាពការងារខុសឆ្ងាយពីនីតិកាលទី១ និងនីតិកាលទី២ ដែលមានត្រឹមតែ៩គណៈកម្មការ ។

អគ្គលេខាធិការដ្ឋានបន្តសិក្សាលើក្របខ័ណ្ឌយុទ្ធសាស្រ្ត និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពស្ថាប័ន(២០១៤-២០២៤) និងទស្សនវិស័យនៃដំណើរទៅមុខរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (២០១៤-២០២៤) ។

ដំណើរការឆ្លងថវិកាព្រឹទ្ធសភា ឆ្នាំ២០១៥ ធ្វើបានមួយជំហានដំបូងដែលបានបង្ហាញនូវលទ្ធផលវិជ្ជមាន ប៉ុន្តែត្រូវឆ្លងកំរិតនយោបាយនៅខែសីហា ឆ្នាំ២០១៤នេះ ។

ភ្នំពេញ,ថ្ងៃទី០៩ ខែ០៨ ឆ្នាំ២០១៤

**អគ្គលេខាធិការ**

**អ៊ុំ-សារិទ្ធ**